# បុគ្គលណាម្នាក់ក៏អាចឆ្លងជំងឺអុតស្វាបានដែរ

តាមរយៈការរួមភេទ ឬទំនាក់ទំនងជិតស្និទ្ធជាមួយនឹងនរណាម្នាក់ដែលមានជំងឺអុតស្វា ឬសម្ភារ ដែលបានប្រឡាក់នឹងមេរោគអុតស្វា

## របៀបដែលជំងឺអុតស្វារីករាលដាលបាន៖

ជំងឺអុតស្វាអាចរីករាលដាលនៅពេលដែលមនុស្សម្នាក់មានទំនាក់ទំនងជិតស្និទ្ធជាមួយនឹងមនុស្សម្នាក់ដែលមានមេរោគអុតស្វា ឬនៅពេលមនុស្សម្នាក់បានប៉ះពាល់ទៅនឹងសម្ភារ (ដូចជាកម្រាលពូក ឬស្រោមខ្នើយ ឬកន្សែងជូតខ្លួន) ដែលបានប្រឡាក់ទៅនឹងមេរោគនោះ។

**មេរោគអុតស្វាអាចរីករាលដាលតាមរយៈ៖**

- ការប៉ះពាល់ទៅនឹងដំបៅអុតស្វានៅលើស្បែករបស់មនុស្សម្នាក់
- ការប៉ះពាល់ទៅនឹងសម្ភារ ឬសាច់ក្រណាត់នានា (សម្លៀកបំពាក់ កម្រាលពូក ឬស្រោមខ្នើយ កន្សែងជូតខ្លួន) ដែលបានប្រឡាក់ទៅនឹងមេរោគ និងផ្ទៃនានា ដែលបានប៉ះពាល់ដោយបុគ្គលដែលមានជំងឺអុតស្វា
- ការប៉ះពាល់ទៅនឹងតំណក់ទឹកតូចៗតាមផ្លូវដង្ហើម ឬសារធាតុរាវផ្សេងៗដែលចេញពីភ្នែក ច្រមុះ និងមាត់ របស់បុគ្គលដែលមានជំងឺអុតស្វា

## ដើម្បីទប់ស្កាត់ការរីករាលដាលនៃមេរោគអុតស្វា បុគ្គលទាំងឡាយគួរតែជៀសវាង៖

1. **ទំនាក់ទំនងជិតស្និទ្ធជាមួយនឹងបុគ្គលដែលមានជំងឺអុតស្វា**
   រួមមានដូចជា ការឱប ការម៉ាស្សា ការថើប ឬការនិយាយនៅក្បែរគ្នា

2. **ការរួមភេទជាមួយនឹងបុគ្គលដែលមានជំងឺអុតស្វា**
   រួមមានដូចជា ការរួមភេទតាមមាត់ តាមទ្វារធំ និងតាមទ្វារមាស ឬក៏ការប៉ះពាល់ប្រដាប់ភេទ ឬតំបន់ទ្វារធំ

3. **ការប្រើប្រាស់របស់របររួមគ្នាជាមួយនឹងបុគ្គលដែលមានជំងឺអុតស្វា**
   រួមមានដូចជា ការប៉ះពាល់ទៅនឹងសាច់ក្រណាត់ ឬផ្ទៃ ឬក៏សម្លៀកបំពាក់នានាដែលប្រើប្រាស់រួមគ្នា

**សម្រាប់ព័ត៌មានបន្ថែមអំពីជំងឺអុតស្វា សូមចូលទៅកាន់គេហទំព័រ៖**
ph.lacounty.gov/media/Monkeypox/

06/30/2022 (Cambodian)

County of Los Angeles Public Health